ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
A P S A R A

លេខ៖ ៣០៤/ខប.លជណ
/២៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអនុវត្តវិធានការនានា នារដូវវស្សា និងផ្សេងៗ ក្នុងរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូន សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមអ្នកបើកបររថយន្តដឹកជញ្ជូនភ្ញៀវទេសចរ អ្នកបើកបរដឹកជញ្ជូនភ្ញៀវទេសចរ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ មេត្តាជ្រាបថា ក្នុងគោលបំណងរក្សាឱ្យបាននូវបទពិសោធន៍ទស្សនា ប្រកបដោយភាពសប្បាយរីករាយ និងក្នុងគោលដៅបង្ការផលប៉ះពាល់ ព្រមទាំងធានាបាននូវសុវត្ថិភាពជាអតិបរមា នារដូវវស្សា ជូនភ្ញៀវទេសចរជាតិ/អន្តរជាតិ និងសាធារណជនទាំងអស់ក្នុងដំណើរកំសាន្ត និងឆ្លងកាត់រមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក អាជ្ញាធរជាតិអប្សរាសូមរំលឹកអំពីវិធានការគួរអនុវត្តមួយចំនួន ដូចខាងក្រោម៖

**១-សុវត្ថិភាពពីបាតុភូតធម្មជាតិ**

- **គ្រោះថ្នាក់ពីដើមឈើ៖** សូមកុំចតយានយន្តគ្រប់ប្រភេទក្រោមដើមឈើនៅពេលខ្យល់កន្ត្រាក់ ឬភ្លៀងខ្លាំងដែលអាចបណ្តាលឱ្យសភាពដីទន់ជ្រាយខ្លាំង បង្កទៅជាការបាក់មែក ឬរលំដើមឈើ ជាយថាហេតុ
- **ប្រយ័ត្នផ្គររន្ទះ៖** ក្នុងករណីមេឃខ្មៅ ធ្លាក់ភ្លៀង ឬមានផ្គររន្ទះខ្លាំង សូមចៀសវាងការប្រើឧបករណ៍អេឡិចត្រូនិច និងកុំជ្រកក្រោមដើមឈើធំៗ

**២-ការរៀបចំខ្លួន និងសម្លៀកបំពាក់**

- **ស្បែកជើង៖** គួរប្រើប្រាស់ស្បែកជើង ដែលមានសភាពស្អិតល្អ ពីព្រោះថ្មប្រាសាទអាចនឹងមានសភាពរអិលខ្លាំងនៅពេលសើម
- **អាវភ្លៀង និងឆ័ត្រ៖** គួរត្រៀមអាវភ្លៀង ឬឆ័ត្រ ដែលមិនមានចុងស្រួចខ្លាំង (អាចប៉ះពាល់ថ្ម និងចម្លាក់ប្រាសាទ) និងចៀសវាងប្រើប្រាស់សម្ភារទាំងនោះ ដែលមានស្លាកសញ្ញា (Logo) តំណាងឱ្យការផ្សព្វផ្សាយផលិតផលគ្រឿងស្រវឹង ផ្ទុយពីគោលការណ៍គ្រប់គ្រងបេតិកភណ្ឌពិភពលោក
- **គោរពក្រមសីលធម៌៖** ស្លៀកពាក់ឱ្យបានសមរម្យ និងអនុវត្តវិធានផ្សេងៗទៀត ដូចមានកំណត់ក្នុងក្រមប្រតិបត្តិអង្គរ ជូនភ្ជាប់មកជាមួយសេចក្តីជូនដំណឹងនេះ

**៣-ផ្សេងៗ**

- **ការការពារសត្វល្អិត៖** គួរលេបថ្នាំការពារសត្វល្អិត ដោយសាររដូវវស្សា អាចនឹងមានសត្វល្អិតច្រើននៅតំបន់មានព្រៃ



អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: apsaraauthorityinfo@gmail.com
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

- គោរពស្លាកសញ្ញាព្រមាននានា៖ អនុវត្តទៅតាមស្លាកសញ្ញាឱ្យដំណឹងនានា ជាពិសេសគោរពតាមការណែនាំរបស់ភ្នាក់ងារទេសចរណ៍ និងភ្នាក់ងារសណ្តាប់ធ្នាប់ប្រចាំការនៅតាមទីតាំងនីមួយៗ
- **អំពីសត្វស្វា៖** ចៀសវាងជាដាច់ខាតការផ្តល់ចំណី និងការប៉ះពាល់ផ្ទាល់ជាមួយសត្វស្វាពីព្រោះសកម្មភាពទាំងនេះ នឹងផ្តល់ផលអាក្រក់ ច្រើនជាងផលល្អ ធ្វើឱ្យខាតដល់ឥរិយាបថធម្មជាតិរបស់សត្វ ធ្វើឱ្យសត្វពឹងផ្អែកលើមនុស្ស និងអាចបង្កជាបញ្ហាសុខភាពធ្ងន់ធ្ងរ ដូចជាបង្កើនហានិភ័យនៃជំងឺ ការប្រឈមមុខដាក់គ្នារវាងមនុស្ស និងសត្វ ប្រកបដោយគ្រោះថ្នាក់ជាដើម។ តាមរយៈនេះសូមទុកឱ្យសត្វរស់នៅតាមបែបធម្មជាតិ មានសុខភាពល្អ និងមានសេរីភាព។ល។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ សមាគមអ្នកបើកបររថយន្តដឹកជញ្ជូនភ្ញៀវទេសចរ អ្នកបើកបរដឹកជញ្ជូនភ្ញៀវទេសចរ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តតាមការគួរ។

ថ្ងៃចន្ទ ១០រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

សៀមរាប ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៦

**អាជ្ញាធរជាតិអប្សរា**